# អេស៊ីលីដា ត្រេននីង សេនធ័រ
# ACLEDA Training Center Ltd.

**ការិយាល័យកណ្តាល**
លេខ : អត្រស ១៨៨១ /១៥

**អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ**
**គោរពជូន**

- **តំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺននៃ នាយកដ្ឋានហិរញ្ញប្បទានពាណិជ្ជកម្ម**
- **តំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺននៃ នាយកដ្ឋានសេវាឥណទាន**
- **នាយក-នាយិកា ធនាគារ អេស៊ីលីដា ភីអិលស៊ី គ្រប់សាខារាជធានី-ខេត្ត-ក្រុង និងសាខាស្រុកកម្រិត " ក "**

**កម្មវត្ថុ :** **វគ្គបំពាក់បំប៉នស្តីពី ការពង្រឹងសមត្ថភាពលើកិច្ចការឥណទាន**

**យោង :**
- សេចក្តីសម្រេចលេខ: អត្រស ០៩៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ គោលការណ៍ប្រតិបត្តិ ហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្ស។
- អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ និងគាំទ្រ លើសេវាហ្វឹកហ្វឺនផ្ទៃក្នុងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និង អេស៊ីលីដា ត្រេននីង សេនធ័រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ និងការធ្វើវិសោធនកម្ម ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ ។
- ផែនការហ្វឹកហ្វឺនរបស់នាយកដ្ឋានឥណទានឆ្នាំ២០១៤ ។
- លិខិតលេខ : កធម ២៣៤៤/១៤ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤ ស្តីពីតម្រូវការរៀបចំបើកវគ្គបំពាក់បំប៉នការងារឥណទាន ។

តបតាមកម្មវត្ថុ និងយោងខាងលើ អេស៊ីលីដា ត្រេននីង សេនធ័រ នឹងមានរៀបចំបើកវគ្គបំពាក់បំប៉នស្តីពី ការពង្រឹងសមត្ថភាពលើកិច្ចការឥណទានដល់**ប្រធានភ្នាក់ងារឥណទាន និងប្រធានភ្នាក់ងារហិរញ្ញប្បទាន ពាណិជ្ជកម្មគ្រប់សាខាកម្រិត" ក " និងនាយកដ្ឋានដែលពាក់ព័ន្ធ**ដែលនឹងប្រព្រឹត្តទៅជា **ពីរវគ្គ** ៖

**<u>វគ្គទី១</u> : ថ្ងៃទី ២៥ ដល់ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៤**

**<u>វគ្គទី២</u> : ថ្ងៃទី ០៣ ដល់ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៤**

នៅ**អេស៊ីលីដា ត្រេននីង សេនធ័រ ជាន់ទី៤ បន្ទប់ប្រាសាទបន្ទាយស្រី** ។

✪ **<u>បញ្ជាក់</u>** : - **ចំពោះសាខាដែលមិនទាន់មានប្រធានភ្នាក់ងារឥណទានសូមលោក-លោកស្រីនាយក-នាយិកាសាខាចាត់ចែងតំណាងភ្នាក់ងារដែលពាក់ព័ន្ធចំនួន១នាក់ ដើម្បីចូលរួមក្នុងវគ្គបំពាក់បំប៉ននេះ។**
- **សិក្ខាកាមដែលចូលរួមត្រូវយកម៉ាស៊ីនគិតលេខមកជាមួយ។**

អាស្រ័យហេតុនេះ សូមលោកនាយក-នាយិកា មេត្តាចាត់បញ្ជូនកម្មករនិយោជិតដែលមានមុខតំណែងដូចខាងលើឲ្យចូលរួមក្នុងវគ្គបំពាក់បំប៉នតាមកាលបរិច្ឆេទ និងទីកន្លែងដូចបានជម្រាបជូន។

សូមលោកនាយក-នាយិកា ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤

**ជ, អគ្គនាយក**

**នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត**

This is an electronic letter sent by Sovanne Tourt

**<u>ជូនភ្ជាប់មកជាមួយ</u>**

- កាលវិភាគវគ្គបំពាក់បំប៉ន
- បញ្ជីឈ្មោះសាខា

**<u>ចម្លងជូន</u>**

- នាយកប្រតិបត្តិឥណទាន
- នាយកប្រតិបត្តិសេវាឥណទាន
- នាយកប្រតិបត្តិហិរញ្ញប្បទានពាណិជ្ជកម្ម
- នាយកការិយាល័យនីតិកម្ម
- នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
- នាយកការិយាល័យគ្រប់គ្រងហានិភ័យ
- នាយកគ្រប់ការិយាល័យសវនកម្ម
- ជំនួយការនាយិកាការិយាល័យធនធានមនុស្ស
  « **ដើម្បីជូនជ្រាបជាព័ត៌មាន** »
- ឯកសារ-កាលប្បវត្តិ